**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការប្រើប្រាស់ប័ណ្ណឆ្លងដែននៅតាមច្រកទ្វារព្រំដែន កម្ពុជា-ថៃ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យ លេខ ០៧អនក្រ ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញកិច្ចព្រមព្រៀងស្តីពីការឆ្លងកាត់ព្រំដែនរវាងប្រទេសទាំងពីរកម្ពុជា-ថៃ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៧
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- តាមលទ្ធផលនៃកិច្ចប្រជុំគណៈរដ្ឋមន្ត្រីចំរុះក្រៅផ្លូវការកម្ពុជា-ថៃ នៅខេត្តសៀមរាប និងខេត្តឧបុិនរាជធានី ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៣
- តាមសភាពការណ៍ចាំបាច់

## សំរេច

**មាត្រា១.-**

ត្រូវបានបង្កើត និងអនុញ្ញាតឱ្យប្រជាពលរដ្ឋខ្មែរដែលរស់នៅតាមខេត្តជាប់ព្រំដែន កម្ពុជា-ថៃ ប្រើប្រាស់ប័ណ្ណឆ្លងដែន ០២ប្រភេទ គឺប័ណ្ណឆ្លងដែនពណ៌ខៀវ និងប័ណ្ណឆ្លងដែនពណ៌លឿង ។

**មាត្រា២.-**

សមត្ថកិច្ចដែលត្រូវផ្តល់ប័ណ្ណឆ្លងដែន កម្ពុជា -ថៃ មាន ៖

- អភិបាលខេត្ត-ក្រុងជាប់ព្រំដែន ចេញប័ណ្ណឆ្លងដែនពណ៌ខៀវ ឱ្យដល់ប្រជាពលរដ្ឋខ្មែរដែលរស់នៅទូទាំង ខេត្ត-ក្រុង ជាប់ព្រំដែន
- នាយនគរបាលអន្តោប្រវេសន៍ ឬនាយនគរបាលការពារព្រំដែនគោកប្រចាំការនៅច្រកទ្វារព្រំដែន ចេញប័ណ្ណឆ្លងដែន ពណ៌លឿង ឱ្យដល់ប្រជាពលរដ្ឋខ្មែរដែលរស់នៅក្នុងស្រុក-ខ័ណ្ឌជាប់ព្រំដែន ។

**មាត្រា៣.-**

- ប្រជាពលរដ្ឋខ្មែរប្រើប្រាស់ប័ណ្ណឆ្លងដែន អាចធ្វើដំណើរពីខេត្តជាប់ព្រំដែន នៃព្រះរាជាណាចក្រកម្ពុជាឆ្លងចូល ទៅខេត្តជាប់ព្រំដែនទល់មុខគ្នានៃព្រះរាជាណាចក្រថៃ
- ក្នុងជំហានដំបូង ប្រជាពលរដ្ឋខ្មែរប្រើប្រាស់ប័ណ្ណឆ្លងដែន អាចធ្វើដំណើរពីខេត្តបន្ទាយមានជ័យ ឆ្លងព្រំដែនទៅខេត្តប្រាជីនបុរី ដោយឆ្លងកាត់ខេត្តស្រះកែវ នៃព្រះរាជាណាចក្រថៃ
- ចំពោះប្រជាពលរដ្ឋថៃ អាចធ្វើដំណើរចេញពីខេត្តស្រះកែវមកខេត្តសៀមរាប ដោយឆ្លងកាត់តាមខេត្តបន្ទាយមានជ័យ ។

**មាត្រា៤.-**

ប័ណ្ណឆ្លងដែនទាំងពីរប្រភេទ ដែលអនុញ្ញាតអោយប្រជាពលរដ្ឋខ្មែររស់នៅតាមខេត្ត-ក្រុងជាប់ព្រំដែនកម្ពុជាថៃ ចូលទៅស្នាក់នៅក្នុងខេត្ត នៃព្រះរាជាណាចក្រថៃ ដូចមានចែងក្នុងមាត្រា ៣ នៃអនុក្រឹត្យនេះ មានរយៈពេលមិនលើសពី ០៧ (ប្រាំពីរ) ថ្ងៃ ។

**មាត្រា៥.-**

- ប័ណ្ណឆ្លងដែនពណ៌ខៀវ ដែលចេញឱ្យប្រើប្រាស់ដោយអភិបាលខេត្ត-ក្រុង មានតម្លៃ ២០.០០០ (ម្ភៃពាន់) រៀល មានសុពលភាព ០២ ឆ្នាំ និងអាចពន្យារពេលប្រើប្រាស់បាន ០២ ឆ្នាំទៀត
- ប័ណ្ណឆ្លងដែនពណ៌លឿង ដែលចេញឱ្យប្រើប្រាស់ដោយនាយនគរបាលអន្តោប្រវេសន៍ ឬនាយនគរបាលការពារព្រំដែនគោក មានតម្លៃ ២០.០០០ (ម្ភៃពាន់)រៀល មានសុពលភាព ០២ ឆ្នាំ និងអាចពន្យារពេលប្រើប្រាស់បាន ០២ ឆ្នាំទៀត ។

**មាត្រា៦.-**

នីតិវិធីនៃការផ្តល់ប័ណ្ណឆ្លងដែន ត្រូវកំណត់ដោយឡែកតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា៧.-**

អ្នកក្លែង និងអ្នកប្រើប្រាស់ប័ណ្ណឆ្លងដែនក្លែងក្លាយ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

**មាត្រា៨.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃបណ្តាក្រសួងស្ថាប័នពាក់ព័ន្ធ និងអភិបាលខេត្ត-ក្រុងជាប់ព្រំដែនកម្ពុជា-ថៃ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៩
- ឯកសារ-កាលប្បវត្តិ